ទីស្តីការក្រសួងយុត្តិធម៌

លេខ ២៧ ប្រក រប.កយ-២០០៤

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពី
## របៀបរបបធ្វើការងារ របស់មន្ត្រីនគរបាលយុត្តិធម៌
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/សន/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យបើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩១/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា

-បានឃើញបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលប្រកាសឱ្យប្រើដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC)ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២

-បានឃើញក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៥ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញវាក្យខ័ណ្ឌ ៣ នចំណុចទី១០ មាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

## <u>សម្រេច</u>

**ប្រការ ១** -មន្ត្រីនគរបាលយុត្តិធម៌ ឬមន្ត្រីដែលអាចបំពេញមុខងារ ជាមន្ត្រីនគរបាលយុត្តិធម៌ដូចមានចែងក្នុងមាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៦,៣៨,៩០ និង៩១ ច្បាប់នីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០១/០០៥ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២១០៦ ត្រូវបំពេញភារៈកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវទៅតាមចរិតលក្ខណៈនៃបទល្មើស ។

**ប្រការ ២** -មន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចគឺ៖

-មន្ត្រីនគរបាលយុត្តិធម៌ នាទីកន្លែងដែលបទល្មើសព្រហ្មទណ្ឌកើតមាន ឬ

-មន្ត្រីនគរបាលយុត្តិធម៌ នាទីកន្លែងដែលជនល្មើសត្រូវបានរកឃើញ ឬ

-មន្ត្រីនគរបាលយុត្តិធម៌ នាទីលំនៅដ្ឋានរបស់ជនល្មើស ឬ

-មន្ត្រីនគរបាលយុត្តិធម៌ ដែលក្រសួងយុត្តិធម៌បានប្រគល់សមត្ថកិច្ចឱ្យ ។

**ប្រការ ២** -មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីទាំងឡាយដែលបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដែលបានរៀបរាប់ក្នុងមាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់នីតិវិធីព្រហ្មទណ្ឌ មានកាតព្វកិច្ចអនុវត្តឱ្យបានម៉ឺងម៉ាត់តាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងអនុវត្តនូវរាល់សេចក្តីសម្រេច ឬ ដីកា ឬ សាលក្រម ឬសាលដីកាស្ថាពរទាំងឡាយដែលបង្គាប់បញ្ជាពីព្រះរាជអាជ្ញា ឬ ចៅក្រមដោយផ្ទាល់ ដោយមិនត្រូវអូសបន្លាយពេលវេលា ឬ សំអាងហេតុផលផ្សេងៗដូចជាមានការរង់ចាំបញ្ជាតាមឋានានុក្រមនោះឡើយ ។ នៅពេលអនុវត្តប្រសិនបើមានជួបការលំបាកស្មុគស្មាញមន្ត្រីនគរបាលយុត្តិធម៌ គប្បីសុំគោលការណ៍ពីព្រះរាជអាជ្ញា ឬពីចៅក្រម ឬពីថ្នាក់លើរបស់ខ្លួន ដើម្បីចាត់វិធានការអនុវត្តឱ្យបានសម្រេច ហើយត្រូវរាយការណ៍រាល់សកម្មភាពទាំងនោះជូនថ្នាក់លើតាមឋានានុក្រមដើម្បីជ្រាប លើកលែងតែដីកានាំខ្លួន ដីកាចាប់ខ្លួន ដីកាស្វែងរកចាប់ខ្លួន ដែលត្រូវបញ្ជូនផ្ទាល់ទៅស្នងការនគរបាល ខេត្ត-ក្រុង ឬប្រធានអង្គភាពចំណុះក្រសួងដែលមានការពាក់ព័ន្ធ ហើយស្នងការនគរបាលខេត្ត-ក្រុង ឬប្រធានអង្គភាពពាក់ព័ន្ធទាំងនោះត្រូវចាត់ឱ្យអនុវត្តមិនឱ្យលើសពីមួយសប្តាហ៍ គិតពីថ្ងៃបានទទួលដីកា ។

**ប្រការ ៤** -អភិបាល អភិបាលរងខេត្ត-ក្រុង អភិបាល អភិបាលរងស្រុក-ខណ្ឌ មេឃុំ-ចៅសង្កាត់ មានភារៈកិច្ចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ផង និងមុខងារជាអាជ្ញាធររដ្ឋបាលក្នុងរង្វង់សមត្ថកិច្ចដែនដីផង ។

ក/-ក្នុងមុខងារជាមន្ត្រីអាជ្ញាធររដ្ឋបាលដែនដី អភិបាលខេត្ត-ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្តក្រុង ប្រធានតុលាការខេត្ត-ក្រុង ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមសារាចរអន្តរក្រសួងលេខ ២០៤ ស.រ.៩៥ ចុះថ្ងៃ ០២-០៣-៩៥ ដែលចេញដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ លើកលែងតែចំណុចណាដែលផ្ទុយពីច្បាប់ ។

ខ/-ក្នុងមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដែលមានភារៈកិច្ចបង្ក្រាបបទល្មើសព្រហ្មទណ្ឌ អភិបាល អភិបាលរងខេត្ត-ក្រុង អភិបាល អភិបាលរងស្រុក-ខណ្ឌ មេឃុំ-ចៅសង្កាត់ ត្រូវស្ថិតនៅក្រោមការដឹកនាំសកម្មភាព និងសម្របសម្រួលពីព្រះរាជអាជ្ញា ។

គ/-មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចេញសេចក្តីណែនាំ ឬសេចក្តីបង្គាប់បញ្ជាអ្វីដល់មន្ត្រីក្រោមឱវាទរបស់ខ្លួនដែលមានខ្លឹមសាររារាំង ឬប្រឆាំងនឹងការអនុវត្តន៍សាលក្រម ឬសាលដីកាស្ថាពរ ឬដីកាសម្រេច ឬ សេចក្តីសម្រេចដែលដាក់ចេញដោយតុលាការ ឬ ចៅក្រម ឬ ព្រះរាជអាជ្ញាបានឡើយ ។ អំពើរារាំង ឬ ប្រឆាំងទាំងនេះនឹងត្រូវទទួលការចោទប្រកាន់ និងផ្តន្ទាទោសតាមមាត្រា ៤៥ នៃ ក្រឹត្យច្បាប់លេខ ២៧ ក្រ.ច ចុះថ្ងៃទី១២-០៣-៨៦ ឬច្បាប់ដែលមានចែងពីបទល្មើសប្រភេទនេះ ។

ឃ/-បើមន្ត្រីនគរបាលយុត្តិធម៌ យល់ឃើញថាចៅក្រម ឬព្រះរាជអាជ្ញា ឬក្រឡាបញ្ជីបានប្រព្រឹត្តអំពើខុសឆ្គងណាមួយត្រូវរាយការណ៍ឬប្តឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឬអង្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចាត់វិធានការកែលំអ ឬដាក់វិន័យតាមច្បាប់ ។

**ប្រការ ៥** ក-ក្នុងករណីដែលកើតមានបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅពិនិត្យដល់ទីកន្លែងកើតហេតុ ដើម្បីកត់ត្រានឹងស្វែងរកនូវចរិតលក្ខណៈបទល្មើស ប្រមូលភស្តុតាងនិងរ៉ាប់រងរក្សាទុកនូវតំរុយនៃភស្តុតាងទាំងឡាយកុំឱ្យបាត់បង់ ហើយត្រូវរាយការណ៍ជាបន្ទាន់តាមមធ្យោបាយឆាប់បំផុតនូវព្រឹត្តិហេតុនៃបទល្មើសជាក់ស្តែងនោះ ជូនព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ដើម្បីចុះដឹកនាំប្រតិបត្តិការស្រាវជ្រាវដល់ទីកន្លែងកើតហេតុ និងចាត់វិធានការតាមច្បាប់ជាសមត្ថកិច្ច ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិចាប់និងឃាត់ខ្លួនជនល្មើសក្នុងរយៈពេល៤៨ ម៉ោង ហើយត្រូវប្រញាប់នាំខ្លួនជនល្មើសដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែងនេះទៅប្រគល់ជូនព្រះរាជអាជ្ញា ដោយមិនគិតពីរយៈពេលនៃការដឹកជញ្ជូនជនល្មើសនោះឡើយ ។

ខ/-ក្នុងករណីដែលមានភស្តុតាងជាក់ស្តែងយ៉ាងខ្លាំង ច្បាស់លាស់ ហើយស៊ីសង្វាក់ដែលបញ្ជាក់បានថា ជនសង្ស័យបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមមែនមន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចចាត់វិធានការដូចបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងដែរ ដូចទាំងវិធានការប្រមូលភស្តុតាងចាប់និងឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅព្រះរាជអាជ្ញា ប៉ុន្តែបើជននោះរត់គេចខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចសុំដីកាចាប់ខ្លួនពីព្រះរាជអាជ្ញាបាន

ប្រសិនបើជនសង្ស័យនោះមានសាវតាជាតិច្បាស់លាស់ ។ ក្នុងរយៈពេលនេះវិធានការប្រមូលភស្តុតាងនិងការកសាងសំណុំរឿងត្រូវតែធ្វើឱ្យបានឆាប់ ពុំចាំបាច់រង់ចាំការចាប់ខ្លួនជនល្មើសបាននោះឡើយ ។

គ/-ក្នុងករណីបទល្មើសមិនជាក់ស្តែង ការចាប់ខ្លួនជនជាប់សង្ស័យត្រូវមានដីកាពីចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាជាដាច់ខាត ។ ការនាំខ្លួន ឬ ការចាប់ខ្លួនជនល្មើស ឬជនជាប់ចោទ ឬទណ្ឌិតតាមដីកានាំខ្លួន ឬដីកាចាប់ខ្លួនរបស់ចៅក្រមស៊ើបអង្កេត ឬរបស់តំណាងអយ្យការដែលសំណុំរឿងមាននៅតុលាការរួចហើយការឃាត់ខ្លួនជនទាំងនេះពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ មិនអាចសុំពន្យារពេលលើសពី៤៨ ម៉ោងបានឡើយ ។

**ប្រការ ៦** -ក្នុងករណីពិសេសចាំបាច់ដូចជាបទឧក្រិដ្ឋធ្ងន់ធ្ងរ និងស្មុគស្មាញដែលជនល្មើសត្រូវចាប់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចសុំពន្យារពេលឃាត់ខ្លួនជនសង្ស័យបានរយៈពេលមិនលើសពី២៤ ម៉ោង ដោយមិនគិតពីរយៈវេលាចាំបាច់សម្រាប់ការដឹកជញ្ជូន ។

ការពន្យារពេលនៃការឃាត់ខ្លួននេះ អាចអនុវត្តបានតែក្នុងលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា៣៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់នីតិវិធីព្រហ្មទណ្ឌតែប៉ុណ្ណោះ ។

**ប្រការ ៧** -មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិឆែកឆេរលំនៅដ្ឋានបានតែក្នុងករណីកើតមានបទល្មើសឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែងប៉ុណ្ណោះ ។ ក្នុងករណីកើតមានបទឧក្រិដ្ឋ ឬបទមជ្ឈិមមិនជាក់ស្តែងការឆែកឆេរអាចអនុវត្តបានលុះតែមានដីកាបង្គាប់ឱ្យឆែកឆេរពីតំណាងអយ្យរការ ឬពីចៅក្រមស៊ើបអង្កេត។ រាល់ការឆែកឆេរត្រូវគោរពតាមវិធានដូចខាងក្រោមៈ

-ការឆែកឆេរត្រូវមានសាក្សីយ៉ាងតិចពីររូបចូលរួម សាក្សីអាចជាអ្នកជិតខាង ឬម្ចាស់ផ្ទះ ហើយត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ ឬសមាជិកគ្រួសារនៃជនជាប់សង្ស័យ ។

-សាក្សីទាំងនេះ មិនអាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាកងរាជអាវុធហត្ថដែលជាកម្លាំងចូលរួមក្នុងកិច្ចប្រតិបត្តិការឆែកឆេរនោះឡើយ ។

-ការឆែកឆេរត្រូវធ្វើនៅក្នុងចន្លោះពេលពីម៉ោង៦ព្រឹក ទៅម៉ោង៦ល្ងាចប៉ុណ្ណោះ។ បើផុតកំណត់រយៈពេលនេះទៅ នីតិវិធីនៃការឆែកឆេរនេះនៅមិនទាន់បានបញ្ចប់ទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់នីតិវិធីនៃការឆែកឆេរនោះភ្លាម ហើយត្រូវចាត់កម្លាំងហ៊ុំព័ទ្ធទីកន្លែងឆែកឆេរនោះរង់ចាំបន្តការឆែកឆេរនោះ ទៅថ្ងៃបន្ទាប់ទៀត។

**ប្រការ ៨** -ដែលហៅថា បទល្មើសជាក់ស្តែងពីបទល្មើសទាំងឡាយណាដែលប្រព្រឹត្តដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ប្រការ ៩** -ក្នុងករណីកើតមានបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមមិនជាក់ស្តែងហើយដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលបណ្តឹង ឬបានដឹងអំពីព្រឹត្តិហេតុនៃបទល្មើសនោះដែលកើតមានឡើងនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាប្រញាប់ទៅព្រះរាជអាជ្ញាសាមីទៅថ្នាក់លើរបស់ខ្លួនជាខ្សែបណ្តោយតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានរួចចុះទៅពិនិត្យស្រាវជ្រាវស្វែងរកបទល្មើស និងកសាងសំណុំរឿងព្រហ្មទណ្ឌជូនទៅព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងក្នុងពេលដ៏ខ្លី ហើយរាយការណ៍ជូនទៅថ្នាក់លើរបស់ខ្លួនអំពីសកម្មភាពការងារដែលខ្លួនបានបំពេញដោយភ្ជាប់នូវសេចក្តីចម្លងសំណុំឯកសារផ្សេងៗនៃសំណុំរឿងទៅជាមួយផង ។

ក្នុងករណី ដែលបានទទួលបណ្តឹងទាំងឡាយដែលមិនចូលជាបទល្មើសព្រហ្មទណ្ឌមន្ត្រីនគរបាលយុត្តិធម៌ត្រូវកោះអញ្ជើញម្ចាស់បណ្តឹងឱ្យមកទទួលយកសំណុំរឿងវិញ ដោយពន្យល់គេឱ្យយកទៅដាក់ជូនចំស្ថាប័នមានសមត្ថកិច្ច ជួយបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចប្រសិនបើមានសំណូមពរពីម្ចាស់បណ្តឹងដោយមិនត្រូវតម្កល់ទុកសំណុំរឿងមិនចាត់ការឡើយ ពីព្រោះមន្ត្រីនគរបាលយុត្តិធម៌មានភារៈកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់រដ្ឋ និងរបស់ប្រជាពលរដ្ឋ ។

**ប្រការ ១០** -កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសសំខាន់ៗទាំងឡាយរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការដឹកា

នាំ និងសម្របសម្រួលពីព្រះរាជអាជ្ញាលើនីតិវិធី និងលើវិធានការស៊ើបអង្កេតដើម្បីធានាការកសាងសំណុំរឿងការចោទប្រកាន់ជនល្មើសឱ្យមានប្រសិទ្ធិភាព ។

ដោយឡែករដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិប្រគល់សបត្ថកិច្ចទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាមួយនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរួមទាំងព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិ ធម៌ផងដែរ ។

**ប្រការ ១១** -មន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងកើតហេតុត្រូវសាកសួរយកចម្លើយពីជនរងគ្រោះសាក្សី និងជនល្មើស ឬជនជាប់សង្ស័យ ធ្វើការពិនិត្យទីកន្លែងកើតហេតុ និងដកហូតឃាត់ទុកនូវវត្ថុតាងឱ្យបានត្រឹមត្រូវ កត់ត្រាក្នុងកំណត់ហេតុនូវការពិនិត្យឃើញរបស់ខ្លួន និងលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន ។

នៅក្នុងកំណត់ហេតុនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនូវគោត្តនាម នាម និងមុខងាររបស់អ្នកត្រូវធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវចុះហត្ថលេខា ឬផ្តិតមេដៃអ្នកត្រូវធ្វើកំណត់ហេតុ និងអ្នកចូលរួមព្រមទាំងត្រូវចុះកាលបរិច្ឆេទឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ហើយត្រូវជៀសវាងដាច់ខាតនូវការឆូតលុប ឬបន្ថែមបន្ថយពាក្យ ។

ប្រសិនបើមានការឆូតលុប ឬការបន្ថែមនូវពាក្យ ឬសេចក្តីអ្វីមួយត្រូវចុះនិទ្ទេសបញ្ជាក់ឱ្យបានច្បាស់លាស់នូវសេចក្តីបន្ថែម ឬបន្ថយពាក្យនោះដោយមានចុះហត្ថលេខាទទួលយល់ព្រមពីអ្នកសួរអ្នកឆ្លើយ និងអ្នកធ្វើកំណហាតុ ។

**ប្រការ ១២** -ជាគោលការណ៍ កំណត់ហេតុទាំងឡាយរបស់មន្ត្រីនគរបាលយុត្តិធម៌មិនមែនជាមូលដ្ឋានសម្រាប់បង្ខំឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ជនល្មើសតាមនោះទេ ។ ជាទូទៅកំណត់ហេតុទាំងនោះគឺគ្រាន់តែផ្តល់ព័ត៌មានអំពីធាតុផ្សំទាំងឡាយនៃបទល្មើសសម្រាប់ជាមូលវិចារណ៍របស់តំណាងអយ្យការ និងតុលាការប៉ុណ្ណោះផ្អែកតាមមាត្រា៤១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែមាត្រា៤២ ទៃច្បាប់នេះដែរបានបញ្ជាក់ថា កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ គឺមានន័យថា ត្រូវទុកជាឯកសារដើម ឬ ជាភស្តុតាងដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។

**ប្រការ ១៣** -ចំពោះបទលហុវិញ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់ជាដរាបរហូតដល់មានភស្តុតាងផ្ទុយ ប៉ុន្តែត្រូវមានលក្ខខ័ណ្ឌមួយ គឺភ្នាក់ងារដែលមានសមត្ថកិច្ចធ្វើកំណត់ហេតុត្រូវមានគុណសម្បត្តិដើម្បីពិនិត្យបទល្មើសតាមផ្លូវច្បាប់ផងទើបបាន ។

**ប្រការ ១៤** -មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិពិនិត្យ និងធ្វើប្រតិបត្តិការបង្ក្រាបបទល្មើសដែលកើតមានឡើងជាយថាហេតុទៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួនបានគ្រប់ពេលវេលា វៀរលែងតែបទល្មើសខ្លះដែលច្បាប់តម្រូវឱ្យមានពាក្យបណ្តឹងពីអ្នករងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីជាមុនសិន ។

**ប្រការ ១៥** -ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ដែលជាម្ចាស់បណ្តឹងអាជ្ញា និងជាអ្នកដឹកនាំប្រតិបត្តិការនៃមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបង្ក្រាបបទល្មើស កាលបើបានទទួលព័ត៌មាន ឬសេចក្តីរាយការណ៍ថា មន្ត្រីនគរបាលយុត្តិធម៌បានផ្អិបសំណុំរឿងចោល ឬតម្កល់រឿងទុកមិនចាត់ការ ឬមិនព្រមបញ្ជូនមកព្រះរាជអាជ្ញា ក្រោមមូលហេតុគូភាគីបានព្រមព្រៀងបាក់ដោយ នោះព្រះរាជអាជ្ញាត្រូវចេញបញ្ជាបង្គាប់ឱ្យមន្ត្រីនគរបាលដែលមានសមត្ថកិច្ចនោះចាត់ការជាបន្ទាន់តាមនីតិវិធី ។ មន្ត្រីនគរបាលយុត្តិធម៌ជាគោលការណ៍ត្រូវតែអនុវត្តតាមបញ្ជានេះជាដរាបក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌មិនព្រមអនុវត្តតាមដីកាបង្គាប់ ឬលិខិតបញ្ជារបស់ព្រះរាជអាជ្ញាទេ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់ពីបទរារាំងនីតិវិធីរបស់តុលាការ ដែលមានចែងក្នុងមាត្រា៤៥ នៃក្រឹត្យច្បាប់លេខ ២៧ ក្រ.ច ចុះថ្ងៃទី១២-០៣-៨៦ ឬតាមច្បាប់ផ្សេងទៀតដែលចែងពីបទល្មើសប្រភេទនេះ ។

**ប្រការ ១៦** -ចំពោះជនប្រព្រឹត្តបទល្មើសមជ្ឈិមជាក់ស្តែង ឬបទល្មើសមជ្ឈិមដែលមានភស្តុតាងជាក់ស្តែងយ៉ាងខ្លាំងច្បាស់លាស់និងស៊ីសង្វាក់ ដែលមន្ត្រីនគរបាលយុត្តិធម៌មិនបានចាប់នឹងឃាត់ខ្លួនដោយនភស្តុតាងគ្រប់គ្រាន់រួច

បញ្ជូនមកលោកព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ព្រះរាជអាជ្ញាគប្បីធ្វើដីកាសន្និដ្ឋានស្ថាពរចោទប្រកាន់ជូនរឿងទៅជំនុំជម្រះភ្លាម ដើម្បីចៅក្រមជំនុំជម្រះបានសម្រេចតាមស្មារតីមាត្រា៦៤ ឧច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ តាមស្មារតីមាត្រា ៦៥ នៃច្បាប់នេះ កាលបើយល់ថាគួរសម្រេចបែបនេះ ។

**ប្រការ ១៧** -ក្នុងករណីបទល្មើសមិនជាក់ស្តែងហើយ ដែលមានកម្រិតទណ្ឌកម្មចែងក្នុងច្បាប់មិនលើសពីមួយឆ្នាំ ដែលមន្ត្រីនគរបាលយុត្តិធម៌បានកសាងសំណុំរឿងប្រកបដោយភស្តុតាង នឹងធាតុផ្សំគ្រប់គ្រាន់បញ្ជូនមកព្រះរាជអាជ្ញានោះ ព្រះរាជអាជ្ញាមានសិទ្ធិធ្វើដីកាសន្និដ្ឋានស្ថាពរចោទប្រកាន់ជូនរឿងទៅជំនុំជម្រះផ្ទាល់ តាមមាត្រា៦១ និង ៦៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ ១៨** -មន្ត្រីនគរបាលយុត្តិធម៌ នៃក្រសួងស្ថាប័នទាំងឡាយដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសដែលមានចែងត្រង់ចំណុចទី១០ នៃមាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់នីតិវិធីព្រហ្មទណ្ឌ ក៏ត្រូវស្ថិតនៅក្រោមការដឹកនាំ និងសម្របសម្រួលពីព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងដែរ ។

**ប្រការ ១៩** -ចំពោះបទល្មើសគយ និងរដ្ឋាករ បទល្មើសជលផល បទល្មើសព្រៃឈើ បទល្មើសបរិស្ថាន បទល្មើសគុណភាពទំនិញ។ល។ ដែលភាគច្រើន ជាប្រភេទបទល្មើសជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ដែលមានចង្អុលក្នុងប្រការ១៨ ខាងលើ មានកាតព្វកិច្ចរៀបចំសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានស្ថាពរចោទប្រកាន់ជូនរឿងទៅជំនុំជម្រះភ្លាម ប្រសិនបើជនល្មើសត្រូវបានចាប់ខ្លួននិងឃាត់ខ្លួនដោយមានកំណត់ហេតុត្រឹមត្រូវបញ្ជូនមកជាមួយដើម្បីចៅក្រមជំនុំជម្រះសម្រេចតាមស្មារតីមាត្រា៦៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីបទល្មើសដែលច្បាប់កម្រិតទណ្ឌកម្មចាប់ពីប្រាំឆ្នាំឡើងទៅ ទោះបីអំពើនោះជាបទល្មើសជាក់ស្តែងឬមិនជាក់ស្តែងក៏ដោយព្រះរាជអាជ្ញាត្រូវតែធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបអង្កេតសម្រេចពីការឃុំខ្លួន ឬឱ្យនៅក្រៅឃុំបណ្តោះអាសន្នតាមមាត្រា៧៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣-១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ព្រមទាំងចាត់ការតាមនីតិវិធីព្រហ្មទណ្ឌបន្ត ។

**ប្រការ ២០** -មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចចំពោះបទល្មើស ដែលមានចរិតពិសេសតាមច្បាប់ដោយឡែកពីបទល្មើសព្រហ្មទណ្ឌសាមញ្ញ ហើយដែលមានចែងអោយផ្តន្ទាទោសដាក់ពន្ធនាគារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារផងនិងពិន័យជាប្រាក់ផង ឬត្រូវរឹបអូសវត្ថុតាំងព្រមទាំងមធ្យោបាយប្រព្រឹត្តបទល្មើសផងនោះមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងស្ថាប័នសាមីមានភារៈកិច្ចធ្វើកំណត់ហេតុបទល្មើស ប្រមូលភស្តុតាងនានានៃបទល្មើស និងចាប់ឃាត់ខ្លួនជនល្មើសបញ្ជូនទៅអបត្យការអមតុលាការខេត្ត-ក្រុង សមត្ថកិច្ចជាដរាបក្នុងរយៈពេលដ៏ខ្លីបំផុតតាមស្មារតីមាត្រា៣៩-៩០-៤១-៤២-៤៣-៤៤-៤៥-៤៦-៤៧-និងមាត្រា៤៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌលើកលែងតែអំពើដែលត្រូវពិន័យអន្តរការណ៍ដោយសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលនៃក្រសួងស្ថាប័នសាមី ។ ករណីនេះប្រសិនបើជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរកាណ៍ទេ ទើបមន្ត្រីនគរបាលយុត្តិធម៌នស្ថាប័នសាមីរៀបចំសំណុំរឿងប្តឹងទៅព្រះរាជអាជ្ញា ដើម្បីចាត់ការតាមច្បាប់ ។

ដោយឡែកចំពោះទំនិញដែលលេចចេញពីអំពើរបស់ម្ចាស់ទំនិញដែលមានចែងក្នុងប្រការ ៣ នៃប្រកាសលេខ២៥៧-ប្រក-សហវ-គរ ចុះថ្ងៃទី១៨-០៧-១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងលើទំនិញនាំចូល តើអំពើរបស់ម្ចាស់ទំនិញនោះពុំមានចរិតលក្ខណៈជាបទល្មើសគយ និងរដ្ឋាករទេ ។ ដូច្នេះប្រសិនបើមានអំពើបែបនេះកើតឡើង គប្បីមន្ត្រីរដ្ឋបាលនៃទីស្នាក់ការគយ និងរដ្ឋាកររៀបចំណុំរឿងប្តឹងទៅតុលាការរដ្ឋប្បវេណីនៃខេត្ត-ក្រុង ដែលទំនិញនោះតាំងនៅដើម្បីសុំអោយតុលាការសម្រេចរឹបអូសលក់ឡាយឡុងសម្រាប់យកប្រាក់ទៅចាត់ចែងតាមប្រការ ៥ នៃប្រកាសស្តីពីការគ្រប់គ្រងលើទំនិញនាំចូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះតាមការកំណត់ ។

**ប្រការ ២១** -បង្កើតគរបាលយុត្តិធម៌ទាំងឡាយដែលមានភារៈកិច្ចអនុវត្តសេចក្តីសម្រេច ឬដីកា សាលក្រមឬសាលដីកាស្ថាពររបស់តុលាការរបស់ចៅក្រម ឬរបស់តំណាងអយ្យការ ត្រូវស្ថិតក្រោមការណែនាំ នឹងត្រួតពិនិត្យពី

ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង មន្ត្រីនគរបាលយុត្តិធម៌មានភារៈកិច្ចត្រូវកំណត់កាលបរិច្ឆេទជាក់លាក់ជាមួយព្រះរាជអាជ្ញា ដែលច្បាប់ប្រគល់សិទ្ធិឱ្យអនុវត្ត ដោយមិនត្រូវរង់ចាំមានបញ្ជាតាមឋានានុក្រមទេ ប៉ុន្តែនៅពេលអនុវត្តប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌យល់ឃើញថាមានភាពស្មុគស្មាញ ត្រូវស្នើសុំគោលការណ៍ថ្នាក់លើរបស់ខ្លួនដើម្បីចាត់វិធានការអនុវត្តឱ្យបានសម្រេចតាមកាលបរិច្ឆេទដែលបានកំណត់ទុក ហើយត្រូវរាយការណ៍ពីសកម្មភាពអនុវត្តទាំងឡាយតាមការណែនាំរបស់ព្រះរាជអាជ្ញាជូនថ្នាក់លើរបស់ខ្លួនជាព័ត៌មាន ដើម្បីជួយមានវិធានការទប់ស្កាត់ភាពអសកម្មទាំងឡាយនៃការអនុវត្តន៍ ។

**ប្រការ ២២** -ការនាំខ្លួនពិរុទ្ធជនពីមន្ទីរឃុំឃាំងមកកាន់ទីសវនាការ ឬមកយកចម្លើយតាមដីកាបង្គាប់របស់ព្រះរាជអាជ្ញា ឬចៅក្រម ឬតុលាការ គឺមន្ត្រីអនុរក្សពន្ធនាគារសាមីមានភារៈកិច្ចទទួលខុសត្រូវក្នុងការចាត់ការឱ្យបានសម្រេចតាមកាលកំណត់ ។

ដីកាបង្គាប់នេះ ត្រូវបញ្ជូនឱ្យដល់មន្ត្រីអនុរក្សពន្ធនាគារមានសមត្ថកិច្ចយ៉ាងតិចបំផុតមួយសប្តាហ៍មុនកាលបរិច្ឆេទដែលបានកំណត់ដោយព្រះរាជអាជ្ញា ឬចៅក្រម ឬតុលាការ រាល់មធ្យោបាយ និងសោហ៊ុយចំណាយផ្សេងៗជាបន្ទុករបស់ប្រធានមន្ទីរឃុំឃាំងសាមី ដែលមានភារៈកិច្ចបំពេញបែបបទ និងលើកគំរោងសុំថវិការដ្ឋ ។

ចំណែកការនាំខ្លួនពិរុទ្ធជន ឬជនជាប់ចោទពីមន្ទីរឃុំឃាំងខេត្ត-ក្រុង មកសាលាឧទ្ធរណ៍ ឬតុលាការកំពូល ឬពីខេត្ត-ក្រុង មួយទៅខេត្ត-ក្រុងមួយ ប្រធានមន្ទីរឃុំឃាំងខេត្ត-ក្រុង សាមីជាអ្នកទទួលខុសត្រូវក្នុងការចាត់ចែងនិងបំពេញបែបបទសុំគោលការណ៍ថ្នាក់លើរបស់ខ្លួន និងលើកគំរោងផែនការចំណាយដើម្បីសុំថវិការដ្ឋ។

**ប្រការ ២៣** -ចំពោះការអនុវត្តន៍ដីកានាំខ្លួន ដីកាចាប់ខ្លួន ដីកាស្វែងរកចាប់ខ្លួនរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចត្រូវយកស្មារតីទទួលខុសត្រូវខ្ពស់អនុវត្តឱ្យបានក្នុងរយៈពេលដ៏ខ្លីបំផុតដែលអាចធ្វើបាន ។ ក្នុងករណីមិនអាចរកឃើញជនដែលត្រូវនាំខ្លួន ចាប់ខ្លួន ឬស្វែងរកចាប់ខ្លួនទេ មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលភារៈកិច្ចនេះត្រូវរាយការណ៍ជូនស្ថាប័នដែលចេញដីកានេះក្នុងរយៈពេលមួយខែយ៉ាងយូរគិតពីថ្ងៃបានទទួលដីកា ។

**ប្រការ ២៤** -មាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់នីតិវិធីព្រហ្មទណ្ឌ ចាត់ទុកកងរាជអាវុធហត្ថជាមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចអនុវត្តចំពោះតែបទល្មើសដែលពាក់ព័ន្ធ នឹងកិច្ចការយោធាប៉ុណ្ណោះ ។ ករណីបទល្មើសព្រហ្មទណ្ឌសាមញ្ញជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត ដែលមានដែនសមត្ថកិច្ចដូចបានកំណត់ក្នុងមាត្រា ៣៦ថ្មី នៃច្បាប់ខាងលើនេះ ។ ចំពោះបទល្មើសព្រហ្មទណ្ឌសាមញ្ញ ក្រៅពីបទល្មើសដែលពាក់ពន្ធ័នឹងកិច្ចការយោធា ប៉ុន្តែជាប្រភេទបទល្មើសជាក់ស្តែងដែលខ្លួនបានជួបជាយថាហេតុ បានទទួលបណ្តឹងអោយជួយជាបន្ទាន់ក្នុងកាលៈទេសៈដែលអវត្តមានមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ច កងរាជអាវុធហត្ថអាចធ្វើការចាប់ខ្លួនជនល្មើសធ្វើកំណត់ហេតុ ប្រមូលភស្តុតាងបញ្ជូនទៅព្រះរាជអាជ្ញាភ្លាមដោយមិនអនុញ្ញាតអោយធ្វើការឃាត់ខ្លួនទុកក្នុងទីតាំងរបស់ខ្លួនឡើយ ។ ក្នុងករណីមិនអាចបញ្ជូនទៅព្រះរាជអាជ្ញាបានទាន់ពេលទេ កងរាជអាវុធហត្ថត្រូវបញ្ជូនទៅមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតាមកំណត់ច្បាប់ និងចាត់ការបន្ត កងរាជអាវុធហត្ថជាកម្លាំងសាធារណៈដែលព្រះរាជអាជ្ញាអាចកេណ្ឌកម្លាំងនេះអនុវត្តសេចក្តីសម្រេច ឬដីកា ឬសាលក្រម ឬសាលដីកាស្ថាពរទាំងឡាយដែលមាន សុពលភាព និងគតិយុត្តបានតាមមាត្រា ៥៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ២៥** -រៀងរាល់បំណាច់ខែនីមួយៗ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងស្ថាប័នដែលមានចែងត្រង់ចំណុច ១០ នៃមាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់នីតិវិធីព្រហ្មទណ្ឌ ត្រូវធ្វើបញ្ជីស្ថិតិសំណុំរឿងដែលអង្គការទាំងនោះបានសម្រេចពិន័យអន្តរការណ៍ ព្រមទាំងរបាយការណ៍ស្តីពីចំនួនទឹកប្រាក់ពិន័យដែលទារបានដាក់ចូលថវិការដ្ឋជូនមកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ឱ្យបានទៀងទាត់ ។ ក្នុងករណីខកខានមិនបានរាយការណ៍ហើយត្រូវបានរកឃើញថាមានការគៃបន្លំ ត្រូវចោទប្រកាន់ និងផ្តន្ទាទោសពីបទកិបកេងទ្រព្យសម្បត្តិរដ្ឋ ឬ តាមច្បាប់ផ្សេងទៀតដែលចែងអំពីបទល្មើសប្រភេទនេះ ។

**ប្រការ ២៦** -ក្រៅពីភារៈកិច្ចដែលមានចែងក្នុងប្រការ២៥ ខាងលើ មន្រ្តីនគរបាលយុត្តិធម៌ នៃស្ថាប័នទាំងនេះ ត្រូវចាត់ចែងអនុវត្តសាលក្រម សាលដីកាស្ថាពរ របស់សាលាជម្រះក្តីគ្រប់ថ្នាក់ក្រោមការណែនាំនិងត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាអមតុលាការ ខេត្ត-ក្រុង នៃដែនដីសមត្ថកិច្ច ។

រៀងរាល់បំណាច់ខែនីមួយៗ មន្រ្តីនគរបាលយុត្តិធម៌ផ្នែកនេះត្រូវរាយការណ៍ពីលទ្ធផលអនុវត្តសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការបានសម្រេចជូនព្រះរាជអាជ្ញា រួមទាំងចំនួនទឹកប្រាក់ដែលបានបង់ចូលថវិការដ្ឋដោយភ្ជាប់សេចក្តីថតចម្លងវិក័យប័ត្រប្រគល់ទទួលប្រាក់ដាក់ចូលថវិការដ្ឋទៅជាមួយផង ។ ចំពោះសាលក្រម ឬសាលដីកាស្ថាពរ របស់តុលាការ ដែលមិនទាន់បានអនុវត្ត ក៏ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាអមតុលាការខេត្ត- ក្រុង ដែលស្ថិតនៅ ក្នុងរង្វង់សមត្ថកិច្ច ដែនដីរបស់ខ្លួនដែរ ។

**ប្រការ ២៧** -មន្រ្តីនគរបាលយុត្តិធម៌ ត្រូវអនុវត្តតាមប្រកាសណែនាំនេះឱ្យមានប្រសិទ្ធិភាពខ្ពស់តាមភារៈកិច្ចរៀងៗខ្លួន ។

**ប្រការ ២៨** -ប្រកាសស្តីពីរបៀបរបបធ្វើការងាររបស់មន្រ្តីនគរបាលយុត្តិធម៌នេះ លាតសន្ធឹងទៅលើមន្រ្តីនគរបាលយុត្តិធម៌ នៃក្រសួងស្ថាប័នផ្សេងទៀត ដែលច្បាប់បានប្រគល់មុខងារ ជាមន្រ្តីនគរបាលយុត្តិធម៌ផងដែរ ។

**ប្រការ ២៩** -សេចក្តីណែនាំទាំងឡាយណា ដែលផ្ទុយពីប្រកាសណែនាំនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣០** -ប្រកាសណែនាំនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤

**រដ្ឋមន្ត្រី**

**អាង ស៊ីផុង**

**<u>ចម្លងជូន</u>**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-គ្រប់អយ្យការ និងតុលាការខេត្ត-ក្រុង
-ដើម្បីជូនជ្រាប
-ដូចប្រការ ២១ ដើម្បីអនុវត្ត
-ឯកសារ- កាលប្បវត្តិ ។